# សេចក្តីថ្លែងការណ៍រួមរបស់ សម្ព័ន្ធទន្លេកម្ពុជា  អំពីការព្រួយបារម្ភលើការផ្តួចផ្តើមគំនិតនៃដំណើរការនីតិវិធីសម្រាប់ ការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងកិច្ចព្រមព្រៀង ( PNPCA ) ចំពោះគម្រោង សាងសង់ទំនប់វារីអគ្គិសនីប៉ាក់បេង

សម្ព័ន្ធទន្លេកម្ពុជា (Rivers Coalition in Cambodia) មានអង្គការសមាជិកបណ្តាញជាតិចំនួន៥២ អង្គការ ព្រមទាំងអង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិផ្សេងទៀត លើកឡើងពីការព្រួយបារម្ភយ៉ាងខ្លាំងចំពោះ ការជូនដំណឹងរបស់រដ្ឋាភិបាលប្រទេសឡាវ ក្នុងចេតនាសាងសង់ទំនប់វារីអគ្គិនីប៉ាក់បេង នៅលើតួមេនៃដងទន្លេមេគង្គ នឹងការចាប់ផ្តើមរបស់គណៈកម្មាធិការទន្លេមេគង្គ នៃការពិគ្រោះយោបល់ជាមុន ក្រោមនីតិវិធីសម្រាប់ការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងកិច្ចព្រមព្រៀង (PNPCA)។

គម្រោងសាងសង់ទំនប់វារីអគ្គិសនីប៉ាក់បេង ជាគម្រោងទី៣ សាងសង់លើតួមេនៃដងទន្លេមេគង្គក្នុងប្រទេសឡាវ។ គម្រោងនេះស្ថិតនៅក្នុងខេត្តឧត្តមសៃ ប៉ែកខាងជើងនៃប្រទេសឡាវ។ គម្រោងនេះជាប្រភេទ (run-of river) ដែលមានលទ្ធភាពផលិតថាមពលវារីអគ្គិសនីបាន ៩១២មេហ្គាវ៉ាត់។ យោងទៅតាមរបាយការណ៍ក្រុមហ៊ុន **Vientiane Based Datang (Lao) Pak Beng Hydropower Co., Ltd** ដែលទទួលខុសត្រូវក្នុងការសាងសង់ទំនប់វារីអគ្គិសនីប៉ាក់បេង តាំងចិត្តក្នុងការឆ្លើយតប ជាមួយមតិយោបល់របស់ប្រទេសជាសមាជិកគណៈកម្មាធិការជាតិទន្លេមេគង្គ និងដៃគូអភិវឌ្ឍន៍[1]។

នីតិវិធីសម្រាប់ការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងកិច្ចព្រមព្រៀង (PNPCA) គឺជាសមាសធាតុយ៉ាងសំខាន់របស់គណៈកម្មាធិការទន្លេមេគង្គ (MRC) សំរាប់កិច្ចសហប្រតិបត្តិការប្រកបដោយសមធ៌ម និងការគ្រប់គ្រងទន្លេមេគង្គប្រកបដោយនិរន្តរភាព រវាងប្រទេសចំនួន៤ជាសមាជិកនៃទន្លេមេគង្គក្រោមរួមមាន៖ ប្រទេសថៃ ឡាវ កម្ពុជា និងវៀតណាម។ គម្រោងអភិវឌ្ឍន៍មួយនៅលើតួមេនៃដងទន្លេមេគង្គដូចជា៖ ទំនប់វារីអគ្គិសនីប៉ាក់បេង ចាំបាច់ត្រូវតែស្នើសុំពិគ្រោះយោបល់ជាមុន តាមរយៈនីតិវិធី សម្រាប់ការជូនដំណឹងការពិគ្រោះយោបល់ជាមុន និងកិច្ចព្រមព្រៀង (PNPCA)។ យោងតាមកិច្ចព្រមព្រៀងរបស់គណៈកម្មាធិការទន្លេមេគង្គឆ្នាំ ១៩៩៥ គោលបំណងនៃការពិគ្រោះយោបល់ជាមុនគឺអនុញ្ញាតឲ្យរដ្ឋាភិបាល នៃប្រទេសជាសមាជិកផ្សេងទៀត ក្នុងការពិភាក្សានិងវាយតម្លៃ ផលប៉ះពាល់លើការប្រើប្រាស់ទឹក និងឥទ្ធិពលផ្សេងទៀត បណ្តាលមកពីគម្រោងអភិវឌ្ឍន៍។ កិច្ចព្រមព្រៀងទន្លេមេគង្គចែងថា *"ការពិគ្រោះយោបល់ជាមុនមិនមែនទាំងជាសិទ្ធិវេតូ (ជំទាស់ដាច់ណាត់) នឹងការប្រើប្រាស់ទឹក ទាំងក៏មិនមែនជាសិទ្ធិប្រើប្រាស់ទឹកជាឯកតោភាគី ដោយភាគីអាងទន្លេណាមួយ ដោយមិនទទួលខុសត្រូវដល់សិទ្ធិរបស់ភាគីអាងទន្លេផ្សេងទៀតឡើយ"*។

[1] http://www.mrcmekong.org/news-and-events/news/mrc-statement-on-the-occasion-of-pdies-15th-anniversary-2/

ទោះបីយ៉ាងណាក៏ដោយ ក្នុងផ្នែកខ្លះនៃនីតិវិធីសម្រាប់ការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងកិច្ចព្រមព្រៀង(PNPCA) និងនីតិវិធីពិគ្រោះយោបល់ជាមុនត្រូវបានទទួលរងការរិះគន់ និងមានការព្រួយបារម្ភយ៉ាងខ្លាំងពីភាគីពាក់ព័ន្ធក្នុងតំបន់ ចាប់តាំងពីគម្រោងទី១ នៃការសាងសង់ទំនប់វារីអគ្គិសនីសាយ៉ាប៊ូរី នៅលើតួមេនៃដងទន្លេមេគង្គ ក្នុងឆ្នាំ២០១១។ ទោះបីជាមានការឆ្លើយតបច្បាស់លាស់ និងយ៉ាងមានទម្ងន់ពីរដ្ឋាភិបាលប្រទេសជាសមាជិកគណៈកម្មាធិការទន្លេមេគង្គ ប្រឆាំងនឹងការសាងសង់ទំនប់វារីអគ្គិសនីសាយ៉ាប៊ូរី និងស្នើអោយផ្អាកការសាងសង់ក្នុងរយៈពេល១០ឆ្នាំ និងសិក្សាបន្ថែមរាប់បញ្ចូល ការសិក្សាប៉ាន់ប្រមាណពីអាងទន្លេមេគង្គ ប៉ុន្តែរដ្ឋាភិបាលឡាវនៅតែបន្តការសាងសង់គម្រោងនេះដោយមិនខ្វល់ពីមតិយោបល់នាពេលកន្លងមក។ ស្ថានការណ៍កាន់តែធ្ងន់ធ្ងរជាងនេះទៀត រដ្ឋាភិបាលឡាវបានបន្តការសាងសង់ទំនប់វារីអគ្គិសនីទី២លើតួមេនៃដងទន្លេមេគង្គគឺទំនប់វារីអគ្គិសនី ដនសាហុង ក្នុងឆ្នាំ២០១៦។ រដ្ឋាភិបាលប្រទេសជាសមាជិកមានការព្រួយបារម្ភយ៉ាងខ្លាំង ព្រមទាំងប្រឆាំងនឹងដំណើរការសាងសង់ទំនប់វារីអគ្គិសនីសាយ៉ាប៊ូរី ដោយស្នើទិន្នន័យមូលដ្ឋាននៃការសិក្សាប៉ាន់ប្រមាណ និងផលប៉ះពាល់ឆ្លងដែន ប៉ុន្តែមិនត្រូវបានទទួលចម្លើយណាមួយ។ ការអនុម័តរបស់សភាជាតិឡាវទៅលើកិច្ចសន្យាសម្បទានលើការសាងសង់ទំនប់វារីអគ្គិសនីដនសាហុង បានធ្វើឡើង ខណៈពេលដែលសំណូមពរទាំងឡាយរបស់ប្រទេសជាសមាជិកគណៈកម្មាធិការទន្លេមេគង្គរួមមាន៖ ថៃ កម្ពុជា និងវៀតណាម ព្រមទាំងសហគមន៍ផ្នែកខាងក្រោមនៃទន្លេមេគង្គ និងអង្គការសង្គមស៊ីវិលនានា មិនទាន់ត្រូវបានឆ្លើយតប និងដោះស្រាយ។ សំរាប់ការសាងសង់ទំនប់ទាំងពីរ ទំនប់សាយ៉ាប៊ូរី និងដនសាហុង មិនទាន់មានការឆ្លើយតបច្បាស់លាស់ចំពោះសំណួរដែលបានលើកឡើងដោយក្រុមបច្ចេកទេសត្រួតពិនិត្យ របស់លេខាគណៈកម្មាធិការទន្លេមេគង្គ។

តាមបទពិសោធន៍មកដល់ពេលបច្ចុប្បន្ននេះបានបង្ហាញថា៖ មានភ័ស្តុតាងតិចតួចណាស់ដែលជាបញ្ហាប្រឈមត្រូវបានលើក ឡើងក្នុងអំឡុងពេលពិគ្រោះយោបល់ជាមុន នឹងមានឥទ្ធិពលណាមួយប្រកបដោយអត្ថន័យ លើការធ្វើសេចក្តីសំរេចចិត្ត។ នីតិវិធីនៃការពិគ្រោះយោបល់ជាមុន សំរាប់ការសាងសង់ទំនប់វារីអគ្គីសនីសាយ៉ាបូរី និងដនសាហុង ត្រូវបានបរាជ័យ ក្នុងគោលបំណងដើម្បីធានាចំពោះកិច្ចសហប្រតិបត្តិសំរាប់និរន្តភាព និងសមធ៌មនិងលើការប្រើប្រាស់ទឹកនៃទន្លេមេគង្គ ដូចដែលមិនមានការព្រមព្រៀងត្រូវបានសម្រេចរវាងរដ្ឋាភិបាលជាសមាជិក ក្នុងការដោះស្រាយបញ្ហា និងនីតិវិធីនៃការពិគ្រោះយោបល់ជាមុនមិនត្រូវបានដោះស្រាយជាផ្លូវការនៅឡើយ។

គណៈកម្មាធិការទន្លេមេគង្គ និងដៃគូអភិវឌ្ឍន៍អន្តរជាតិ បានទទួលស្គាល់នូវគុណវិបត្តិ និងការខ្វះចន្លោះក្នុងនីតិវិធីនៃការពិគ្រោះយោបល់ជាមុន។ គណៈកម្មាធិការទន្លេមេគង្គបានចាប់ផ្តើមធ្វើការត្រួតពិនិត្យឡើងវិញលើនីតិវិធីសម្រាប់ការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងកិច្ចព្រមព្រៀង (PNPCA) ប៉ុន្តែមិនមានព័ត៌មានពីវឌ្ឍនៈភាព ឬក៏លទ្ធផលនៃការត្រួតពិនិត្យនោះត្រូវបានចែករំលែកជាសារធារណៈ។ លើសពីនេះទៀតការសិក្សារបស់ក្រុមប្រឹក្សាគណៈកម្មាធិការទន្លេមេគង្គ ក្នុងការសិក្សាវាយតម្លៃទូទៅលើអាងទន្លេមេគង្គនៃផលប៉ះពាល់បណ្តាលមកពីទំនប់វារីអគ្គិសនីលើតួមេនៃដងទន្លេមេគង្គ ក្នុងឆ្នាំ២០១១ ដែលបានយល់ព្រមដោយប្រទេសទាំង៤ជាសមាជិក ត្រូវបានពន្យាពេល និងមិនបានបញ្ចប់។

ការសាងសង់ទំនប់វារីអគ្គីសនី ប៉ាក់បេង នឹងធ្វើអោយមានផលប៉ះពាល់យ៉ាងសំខាន់ដល់សហគមន៍ នៅក្នុងប្រទេសថៃ ដែលរស់នៅផ្នែកខាងលើ និងខាងក្រោមនៃគម្រោងសាងសង់ទំនប់។ លើសពីនេះទៀតគម្រោងនេះនឹងគំរាមកំហែងដល់ជីវចំរុះ ធនធានជលផល នៅខ្សែទឹកខាងក្រោមទន្លេមេគង្គ ដែលជាប្រភពសន្តិសុខស្បៀងនៃប្រជាពលរដ្ឋរាប់សិបលាននាក់ និងជាពិសេសបឹងទន្លេសាប ដែលជាបេះដូងនៃប្រទេសកម្ពុជា។

សម្ព័ន្ធទន្លេកម្ពុជា យល់ស្របតាមការព្រួយបារម្ភរបស់ស្ថាប័នអង្គការអន្តរជាតិមួយឈ្មោះអង្គការទន្លេអន្តរជាតិ ដែលបានចេញសេចក្តីថ្លែងការណ៍នាពេលកន្លងមក[2] ជំរុញអោយដោះស្រាយជាបន្ទាន់នូវចំនុចខ្វះខាតលើនិតិវិធីសម្រាប់ការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងកិច្ចព្រមព្រៀង (PNPCA) និងបញ្ហាដែលមិនទាន់មានការឯកភាពគ្នារវាងភាគីប្រទេសសមាជិកទាំងបួន នៃគណៈកម្មាធិការទន្លេមេគង្គមាន៖ កម្ពុជា ឡាវ ថៃ និងវៀតណាម ពាក់ព័ន្ធនឹងការសាងសង់ទំនប់វារីអគ្គីសនី សាយ៉ាប៊ូរី និងដនសាហុង មុននឹងឈានដល់ការពិចារណាលើគម្រោងថ្មីទៀតលើតួមេនៃដងទន្លេមេគង្គ។

យើងខ្ញុំក្នុងនាមជា សមាជិកសម្ព័ន្ធទន្លេកម្ពុជា ព្រមទាំងអង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិ សូមស្នើសុំដល់គណៈកម្មាធិការទន្លេមេគង្គ បញ្ឈប់ការពិគ្រោះយោបល់ជាមុនសំរាប់គម្រោងទំនប់វារីអគ្គិសនី ប៉ាក់បេង និងស្នើជាផ្លូវការអោយរដ្ឋាភិបាលឡាវផ្អាកសកម្មភាពគ្រប់គម្រោង ដើម្បីដោះស្រាយលើគុណវិបត្តិនៃនីតិវិធីសម្រាប់ការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងកិច្ចព្រមព្រៀង (PNPCA) អោយមានប្រសិទ្ធិភាពសិន។ យើងខ្ញុំក៏ ទាមទារលើនីតិវិធី សម្រាប់ការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងកិច្ចព្រមព្រៀង (PNPCA) គួរព្យួរទុករហូតដល់លទ្ធផលនៃការសិក្សារបស់ក្រុមប្រឹក្សាគណៈកម្មាធិការទន្លេមេគង្គត្រូវបានចែករំលែកជាសាធារណៈ។ យើងខ្ញុំជំរុញឲ្យរដ្ឋាភិបាលកម្ពុជាទទួលស្គាល់និងគាំទ្រការស្នើសុំទាំងអស់នេះ។

ប្រសិនបើសំណើរ ក៏ដូចជាក្តីព្រួយបារម្ភរបស់យើងខ្ញុំក្នុងនាមជាអង្គការសង្គមស៊ីវិល និងសហគមន៍ដែលទទួលរងផលប៉ះពាល់ដោយផ្ទាល់នៅផ្នែកខ្សែទឹកខាងក្រោមនៃទន្លេមេគង្គ នៅតែមិនត្រូវបានដោះស្រាយប្រកបដោយលទ្ធផលដែលអាចទទួលយកបានទេនោះ យើងខ្ញុំនឹងនៅតែបន្តដាក់សេចក្តីថ្លែងការណ៍ និងប្រឹងឲ្យអស់លទ្ធភាពនៅក្នុងការស្វែងរកយន្តការ និងក្របខ័ណ្ឌច្បាប់ក្នុងតំបន់ និងអន្តរជាតិនានា ដើម្បីទប់ស្កាត់ការសាងសង់ទំនប់វារីអគ្គិសនីនាពេលអនាគតនៅលើតួទន្លេមេនៃដងទន្លេមេគង្គ។

ខាងក្រោមនេះជាបញ្ជីឈ្មោះអង្គការជាសមាជិកសម្ព័ន្ធទន្លេកម្ពុជា និងអង្គការដៃគូជាតិ និងអន្តរជាតិ ដែលបានចូលរួមយល់ព្រមលើសេចក្តីថ្លែងការណ៍នេះ៖

1) វេទិកា នៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា (The NGO Forum on Cambodia)
2) សមាគមន៍ថែរក្សាបរិស្ថាន និងវប្បធម៌ (Culture and Environment Preservation Association)

[2] https://www.internationalrivers.org/resources/press-release-flawed-prior-consultation-cannot-legitimize-new-mekong-dam-11589

3) អង្គការសម្ព័ន្ធភាពដើម្បីអភិរក្សធនធានជលផល (Fisheries Action Coalition Team)
4) អង្គការភូមិខ្ញុំ (My village)
5) បណ្ដាញការពារទន្លេសេសាន ស្រែពក សេកុង (3S Rivers Protection Network)
6) បណ្ដាញអ្នកថែរក្សាទឹកបឹងទន្លេសាប (Tonle Sap Lake Water Keeper)
7) សម្ព័ន្ធប្រជានេសាទកម្ពុជា (The Coalition of Cambodia Fishers)
8) អង្គការអភិវឌ្ឍន៍ជនបទភូមិភាគឦសាន (Northeastern Rural Development)
9) អង្គការកសិករខ្មែរដើម្បីអភិវឌ្ឍន៍កសិកម្ម (Khmer Farmer Cooperation of Agriculture Development Organization)
10) អង្គការថែរក្សាជនជាតិដើមភាគតិចកម្ពុជា (Save the Vulnerable Cambodia)
11) អង្គការពន្លកខ្មែរ (Ponlok Khmer)
12) អង្គការអេកូសាន់ (Eco Sun)
13) សហគមន៍យុវជនជនជាតិដើមភាគតិចកម្ពុជា (Cambodia Indigenous Youth Association)
14) អង្គការអ្នកអភិវឌ្ឍន៍សហគមន៍ (Nak Aphiwat Sahokkom)
15) អង្គការអភិវឌ្ឍន៍ជនបទកម្ពុជា (Cambodia Rural Development Team)
16) បណ្ដាញយុវជនកម្ពុជា (Cambodia Youth Network)
17) អង្គការសកម្មភាពដើម្បីអភិវឌ្ឍន៍ (Action For Development)
18) អង្គការអភិវឌ្ឍន៍សម្លេងសហគមន៍ (Building Community Voice)
19) សហគមន៍អភិវឌ្ឍន៍ជនបទ (Rural Development Association)
20) អង្គការទឹកដីសុវណ្ណភូមិ (Tekdeysovanphum Organization)
21) សកម្មភាពដើម្បីបរិស្ថាន និងសហគមន៍ (Action on Environment and Community)
22) បណ្ដាញកសាងសន្តិភាពសហគមន៍ (Community Peace Network)
23) អភិវឌ្ឍន៍សហគមន៍កម្ពុជា (Cambodia Community Development)
24) អង្គការគោលដៅយើង (Our Objective Organization)
25) បណ្ដាញសហគមន៍ជនជាតិដើមភាគតិចព្នងខេត្តមណ្ឌលគិរី (Bunong Indigenous Communities Network of Mondulkiri)
26) អង្គការកែប្រែសហគមន៍ (Community Translation Organization)
27) ពន្លឺនៃក្ដីសង្ឃឹម (Ponleu Ney Kdey Sangkhum)
28) អង្គការយុវជនខ្មែរ និងការអភិវឌ្ឍន៍សង្គម (Khmer Youth and Social Development).